# បលាសជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់សង្កិនកិលេស បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ហំសោ បលាសមវច** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ននឹងមានជាក់ច្បាស់ក្នុង**បញ្ញាសជាតក** ។ ចំណែកក្នុងជាតកនេះ ព្រះសាស្តាហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិលេស គឺជារបស់ដែលគប្បីរង្កៀស សូម្បីមានប្រមាណតិចក៏អាចធ្វើឲ្យដល់សេចក្តីវិនាស បីដូចជាដើមជ្រៃ សូម្បីបោរាណបណ្ឌិតទាំងឡាយ ក៏រង្កៀសក្នុងវត្ថុដែលគប្បីរង្កៀស ដូច្នេះហើយ ព្រះអង្គបាននាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសុវណ្ណហង្ស កាលធំហើយ សម្រេចការរស់នៅក្នុងសុវណ្ណគូហា

លើគំនិតក្តួដ តែងមកបរិភោគស្រូវសាលីដែលកើតឯង ក្នុងជាតស្រះ ក្នុងហិមវន្តប្រទេស ។ ក្នុងផ្លូវជាទីទៅមករបស់សុវណ្ណហង្សនោះ មាន**បលាសព្រឹក្ស** (ដើមចារ) ដ៏ធំមួយដើម ។ សុវណ្ណហង្សនោះសូម្បីកាលទៅ តែងសម្រាកលើមហាបលាសព្រឹក្សនោះ ហើយទើបបន្តដំណើរទៅ សូម្បីកាលមក ក៏តែងសម្រាកលើដើមឈើនោះ ហើយទើបធ្វើដំណើរបន្ត ។

លំដាប់នោះ សុវណ្ណហង្សក៏មានសេចក្តីស្និទ្ធស្នាលនឹងទេវតា ដែលកើតនៅនឹងបលាសព្រឹក្សនោះ ។ ក្នុងសម័យខាងក្រោយមក មានបក្សីញីមួយ ទំពាស៊ីផ្លែជ្រៃទុំលើដើមជ្រៃមួយ រួចហើរមកទំលើមែកបលាសព្រឹក្សនោះ ហើយបន្ទោបង់វច្ចៈក្នុងចន្លោះប្រគាបដើមបលាសៈ ។ ពន្លកដើមជ្រៃក៏ដុះក្នុងទីនោះ ក្នុងវេលាមានខ្នាតបាន ៤ ធ្នាប់ ដើមជ្រៃនោះក៏ស្រស់ស្អាត ព្រោះមានស្លឹកក្រហម ។ ស្តេចហង្សឃើញដើមជ្រៃនោះហើយហៅរុក្ខទេវតាមកនិយាយថា ម្នាលបលាសៈសម្លាញ់ ឈ្មោះថា ដើមជ្រៃ ដែលកើតនឹងដើមឈើណា កាលច្រើនហើយ តែងញ៉ាំងដើមនោះឲ្យវិនាស ចូរកុំឲ្យដើមជ្រៃនេះធំឡើយ វានឹងញ៉ាំងវិមានរបស់លោកឲ្យវិនាស លោកចូរដកវាចេញ ហើយបោះចោល ឈ្មោះថា វត្ថុដែលប្រកបដោយសេចក្តីរង្កៀស ក៏គួរដើម្បីនឹងរង្កៀស ដូច្នេះហើយ កាលនឹងប្រឹក្សាជាមួយនឹងបលាសទេវតា ទើបពោលគាថាទី ១ ថា

**ហំសោ បលាសមវច, និគ្រោធោ សម្ម ជាយតិ;**
**អង្កស្មឹ តេ និសិន្នោវ, សោ តេ មម្មានិ ឆេច្ឆតិ។**

***ស្តេចហង្ស បាននិយាយនឹងបលាសទេវតា (ថា) ម្នាលសម្លាញ់ ដើមជ្រៃដុះ ដើមជ្រៃនោះ ដូចសត្រូវអង្គុយលើភ្លៅរបស់អ្នក នឹងកាត់បង់នូវជីវិតសង្ខាររបស់អ្នក ។***

បាទទី ១ (ហំសោ បលាសមវច) ក្នុងគាថានេះ (ជាពាក្យដែល) ព្រះសាស្តាកាលបានត្រាស់ជាព្រះអភិសម្ពុទ្ធហើយ ព្រះអង្គត្រាស់ទុក ។ បទថា **បលាសំ** បានដល់ បលាស-ទេវតា (ទេវតានៅនឹងដើមចារ) ។ បទថា **សម្ម** ប្រែ សម្លាញ់ ។ បទថា **អង្កស្មឹ** ប្រែថា លើភ្លៅ

(ក្នុងទីនេះសំដៅយកប្រគាប) ។ បទថា **សោ តេ មម្មានិ ឆេច្ឆតិ** សេចក្តីថា ដើមជ្រៃនោះចម្រើនធំត្រង់ប្រគាបហើយ នឹងកាត់ជីវិត ដូចជាសត្រូវ ។ លោកហៅជីវិតសង្ខារថា **មម្មានិ** ក្នុងទីនេះ ។

បលាសទេវតាស្តាប់ពាក្យនោះហើយ កាលមិនកាន់យកពាក្យ របស់ស្តេចហង្សនោះ ទើបពោលគាថាទី ២ ថា

**វឌ្ឍតាមេវ និគ្រោធោ, បតិដ្ឋស្ស ភវាមហំ;**
**យថា បិតា ច មាតា ច, ឯវំ មេ សោ ភវិស្សតិ។**

***ខ្ញុំជាទីពឹង របស់ដើមជ្រៃនុះ ដូចជាមាតាបិតា ដើមជ្រៃនុះនឹងជាទីពឹង (របស់ខ្ញុំ) ក្នុងកាលដែលវាចម្រើនឡើង យ៉ាងនោះដែរ ។***

គាថានោះមានសេចក្តីថា ម្នាលសម្លាញ់ អ្នកមិនដឹងនូវដើមជ្រៃនេះ (នឹងជាទីពឹងរបស់ខ្ញុំ) ក្នុងកាលដែលវាធំឡើង មាតាបិតាជាទីពឹងរបស់បុត្រ ក្នុងគ្រាជាកូនតូចយ៉ាងណា ខ្ញុំនឹងជាទីពឹងរបស់ដើមជ្រៃនេះ យ៉ាងនោះ បុត្រទាំងឡាយកាលធំហើយជាទីពឹងរបស់មាតាបិតាដែលចាស់ជរាយ៉ាងណា ដើមជ្រៃនេះនឹងជាទីពឹងរបស់ខ្ញុំ ក្នុងកាលជាក្រោយ ក៏យ៉ាងនោះ ។

លំដាប់នោះ ស្តេចហង្សក៏ពោលគាថាទី ៣ ថា

**យំ ត្វំ អង្កស្មិំ វឌ្ឍេសិ, ខីររុក្ខំ ភយានកំ;**
**អាមន្ត ខោ តំ គច្ឆាម, វុឌ្ឍិ មស្ស ន រុច្ចតិ។**

*អ្នកបណ្ដុះនូវឈើមានជ័រ ដូចទឹកដោះ ដែលគួរខ្លាច ដូចសត្រូវនៅលើភ្លៅ ដោយហេតុណា ហេតុនោះ ទើបយើងប្រាប់អ្នកហើយនឹងទៅ ការចម្រើនឡើងនៃដើមជ្រៃនោះ មិនពេញចិត្ត (ខ្ញុំ) ទេ ។*

*បណ្ដាបទទាំងនោះ បទថា* **យំ ត្វំ** *សេចក្ដីថា ដោយហេតុដែលអ្នកឲ្យ**ខីរព្រឹក្ស** (ដើមឈើមានជ័រដូចទឹកដោះ) ដែលជាអ្នកនាំមកនូវភ័យដោយភាវៈជាអ្នកឲ្យភ័យ ដែលដូចជាសត្រូវ ចម្រើនត្រង់ប្រគាប ។ បទថា* **អាមន្ត ខោ តំ** *សេចក្ដីថា ព្រោះហេតុនោះ ខ្ញុំទើបហៅអ្នកមក កាលឲ្យអ្នកបានដឹងហើយ ខ្ញុំនឹងទៅ ។ បទថា* **វុឌ្ឍិ មស្ស** *សេចក្ដីថា សេចក្ដីចម្រើនរបស់ដើមជ្រៃនោះ មិនពេញចិត្តដល់ខ្ញុំ ។*

*កាលស្ដេចហង្សពោលយ៉ាងនេះហើយ ទើបកាងស្លាបហើរទៅកាន់ភ្នំចិត្តកូដ ។ ចាប់ពីពេលនោះមក ហង្សពោធិសត្វមិនបានមកកាន់ទីនោះទៀត ។ ក្នុងកាលជាក្រោយមក ដើមជ្រៃកាលធំហើយ ក៏មានរុក្ខទេវតាមួយកើតឡើងនៅនឹងដើមជ្រៃនោះ ។ ដើមជ្រៃដែលធំហើយនោះ ក៏ទម្លាយដើមបលាសៈ ញាំងវិមានរបស់ទេវតាមួយអន្ទើដោយមែកទាំងឡាយឲ្យធ្លាក់ចុះ ។ ក្នុងកាលនោះ បលាសទេវតាកំណត់ពាក្យរបស់ស្ដេចហង្ស គិតថា ស្ដេចហង្សនេះឃើញភ័យក្នុងអនាគតទើបពោលយ៉ាងនេះ ចំណែកយើងមិនធ្វើតាមពាក្យរបស់ស្ដេចហង្សនោះ ដូច្នេះ កាលបរិទេវនាការ ទើបពោលគាថាទី ២ ថា*

**ឥទានិ ខោ មំ ភាយេតិ, មហានេរុនិទស្សនំ;**
**ហំសស្ស អនភិញ្ញាយ, មហា មេ ភយមាគតំ។**

*ឥឡូវនេះ ដើមជ្រៃញាំងអញឲ្យភ័យ ភ័យដ៏ធំមកដល់អញ ព្រោះមិនយល់ពាក្យនៃស្ដេចហង្ស ជាពាក្យដូចជាភ្នំសិនេរុដ៏ធំ ។*

*បណ្តាបទទាំងនោះ បទថា* **ឥទានិ ខោ មំ ភាយេតិ** *សេចក្តីថា ដើមជ្រៃនេះ ញាំងឲ្យយើងត្រេកអរក្នុងកាលដែលនៅតូច ឥឡូវនេះ ញាំងយើងឲ្យភ័យខ្លាច ។ បទថា* **មហាធេរុ-ធិទស្សនំ** *សេចក្តីថា យើងស្តាប់ពាក្យរបស់ស្តេចហង្សដែលធំដូចភ្នំសិនេរុហើយ កាលមិនដឹង ទើបមិនដកដើមជ្រៃនោះក្នុងកាលដែលវានៅតូច ។ បទថា* **មហា មេ ភយមាគតំ** *សេចក្តីថា បលាសទេវតាសោកសៅថា ឥឡូវនេះ ភ័យធំមកដល់យើង ។*

*ចំណែកដើមជ្រៃកាលធំហើយ ក៏ទម្លាយដើមបលាសៈ ធ្វើឲ្យនៅសល់ ត្រឹមតែជាដង្គត់ វិមានរបស់ទេវតាក៏បាត់ទៅទាំងអស់ ។*

**៩ តស្ស វុឌ្ឍិ កុសលប្បសត្ថា, យោ វឌ្ឍមានោ ឃសតេ បតិដ្ឋំ;**
**តស្សូបរោធំ បរិសង្កមានោ, បតារយី មូលវធាយ ធីរោ។**

***អន្តរាយណា កាលចម្រើនឡើងរមែងបំផ្លាញនូវទីពឹង សេចក្តីចម្រើននៃអន្តរាយនោះ ជនអ្នកឈ្លាសវៃ មិនសរសើរឡើយ អ្នកប្រាជ្ញកាលរង្កៀសនឹងសេចក្តីវិនាស រមែងព្យាយាម ដើម្បីសម្លាប់នូវមូលហេតុ នៃសេចក្តីអន្តរាយនោះ ។***

*គាថាទី ៩ នេះ ជាអភិសម្ពុទ្ធគាថា ។*

*បណ្តាបទទាំងនោះ បទថា* **កុសលប្បសត្ថា** *សេចក្តីថា ដែលអ្នកឆ្លាតទាំងឡាយសរសើរហើយ ។ បទថា* **ឃសតេ** *មានសេចក្តីថា ទំពាស៊ី អធិប្បាយថា ធ្វើឲ្យវិនាស ។ បទថា* **បតារយី** *សេចក្តីថា ប្រឹងប្រែងព្យាយាម ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុណាកាលចម្រើនឡើង ញាំងទីពឹងរបស់ខ្លួនឲ្យវិនាស សេចក្តីចម្រើនរបស់វត្ថុនោះ បណ្ឌិតទាំងឡាយរមែងមិនសរសើរ ចំណែកអ្នកប្រាជ្ញ គឺអ្នកបរិបូណ៌ដោយញាណ កាលរង្កៀសនឹងសេចក្តីវិនាសយ៉ាងនេះថា សេចក្តីវិនាសនឹងមានដល់យើង ដូច្នេះហើយ តែងព្យាយាមសម្លាប់មូលនៃសេចក្តីវិនាសនោះ ។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ភិក្ខុ ៥០០ រូប បានសម្រេចព្រះអរហត្ត ។*

**តទា សុវណ្ណហំសោ អហមេវ អហោសឹ** *សុវណ្ណហង្ស ក្នុងកាលនោះ គឺតថាគតនេះឯង ។*

*ចប់ បលាសជាតក ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត វណ្ណារោហវគ្គ បិដកលេខ ៥៩ ទំព័រ ២៥)*

*ថ្ងៃពុធ ១១ កើត ខែវិសាខ ឆ្នាំច សំរិទ្ធិស័ក ច.ល. ១៣៨០*

*ថ្ងៃទី ២៥ ខែមេសា ព.ស. ២៥៦១ គ.ស.២០១៨*

*ដោយ ស.ជ.វ.ថ.*